# ដង្វាយធួនអាចព្យាបាលគ្រប់ការឈឺចាប់ទាំងអស់

អែលឌើរ ខេន អេហ្វ រីឆាត
នៃពួកចិតសិបនាក់

*ឧបសគ្គដ៏ធំរបស់យើងនៅក្នុងជីវិតរមែងស្លាប់ គឺការក្លាយទៅជា « អ្នកបរិសុទ្ធ តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ » ។*

ក្នុងនាមខ្ញុំជាពេទ្យវះកាត់ម្នាក់ ផ្នែកមួយដ៏សំខាន់នៃពេលវេលាក្នុងអាជីពរបស់ខ្ញុំត្រូវបានចំណាយទាំងស្រុងទៅលើអ្វីដែលទាក់ទងនឹងការឈឺចាប់ ។ ខ្ញុំបានធ្វើការវះកាត់របួសស្នាមស្ទើរតែរាល់ថ្ងៃ ដោយជៀសមិនរួច — ហើយការខិតខំរបស់ខ្ញុំភាគច្រើន ត្រូវចំណាយដើម្បីទប់ស្កាត់ និងកាត់បន្ថយការឈឺចាប់ ។

ខ្ញុំបានសញ្ជឹងគិតអំពីគោលបំណងនៃការឈឺចាប់ ។ គ្មាននរណាម្នាក់ជៀសផុតពីការឈឺចាប់នោះទេ ។ ខ្ញុំបានឃើញមនុស្សដោះស្រាយបញ្ហានេះតាមរបៀបខុសៗគ្នា ។ អ្នកខ្លះបែរចេញពីព្រះទាំងកំហឹង ខណៈដែលអ្នកខ្លះទៀតបានធ្វើឲ្យការរងទុក្ខរបស់គេនាំគេឲ្យកាន់តែខិតជិតព្រះ ។ ដូចជាអ្នកដែរ ខ្ញុំក៏ធ្លាប់ជួបការឈឺចាប់ដូចគ្នា ។ ការឈឺចាប់គឺជាខ្នាតវាស់វែងពីដំណើរការនៃការព្យាបាល ។ ជាញឹកញាប់ វាបង្រៀនយើងនូវការអត់ធ្មត់ ។

អែលឌើរ អ័រសិន អែហ្វ វិតនី បានសរសេរថា ៖ « គ្មានការឈឺចាប់ និងការសាកល្បងណាមួយដែលយើងទទួល ហើយក្លាយជាឥតបានការនោះទេ ។ វាបង្រៀនយើង ហើយជួយយើងឲ្យអភិវឌ្ឍនូវគុណសម្បត្តិដូចជា ការអត់ធ្មត់ សេចក្តីជំនឿ ភាពរឹងប៉ឹង និងការបន្ទាបខ្លួន... ។ ដោយសារទុក្ខព្រួយ និងការរងទុក្ខ ការលំបាក និងការវេទនា ទើបយើងបាននូវការចេះដឹងដែលយើងមកទីនេះដើម្បីទទួល » ។[1]

ស្រដៀងគ្នានេះដែរ អែលឌើរ រ៉ូបឺត ឌី ហែល បានមានប្រសាសន៍ថា ៖ « ការឈឺចាប់នាំឲ្យអ្នកមានការបន្ទាបខ្លួន ដែលធ្វើឲ្យអ្នកសញ្ជឹងគិត ។ វាគឺជាបទពិសោធន៍ ដែលខ្ញុំមានអំណរគុណក្នុងការស៊ូទ្រាំ ។ ...ខ្ញុំបានរៀនថាការឈឺចាប់ខាងសាច់ឈាម និងការព្យាបាលខាងរាងកាយ បន្ទាប់ពីការវះកាត់ដ៏ធំ គឺមានលក្ខណៈស្រដៀងគ្នាដែលគួរឲ្យកត់សម្គាល់ ទៅនឹងការឈឺចាប់ខាងវិញ្ញាណ និងការព្យាបាលខាងព្រលឹងវិញ្ញាណ នៅក្នុងដំណើរការនៃការប្រែចិត្តដែរ » ។[2]

ទុក្ខវេទនារបស់យើងជាច្រើនមិនចាំបាច់តែជាកំហុសរបស់យើងនោះទេ ។ រឿងរ៉ាវដែលមិនបានរំពឹងទុក កាលៈទេសៈវិវាទ ឬខកចិត្ត ជំងឺ និងសូម្បីតែសេចក្តីស្លាប់ដែលនៅជុំវិញយើង សុទ្ធតែជះឥទ្ធិពលចំពោះបទពិសោធន៍ខាងសាច់ឈាមរបស់យើង ។ ជាងនោះទៅទៀត យើងអាចរងទុក្ខវេទនាដោយសារអំពើរបស់អ្នកដទៃ ។[3]

លីហៃបានកត់សម្គាល់ថា យ៉ាកុបបាន « រងទុក្ខ... និងការសោកសៅជាច្រើន ដោយព្រោះការទ្រគោះរបស់បងៗ [ របស់គាត់ ] » ។[4] ការផ្ទុយគឺជាផ្នែកមួយនៅក្នុងផែនការនៃសុភមង្គលរបស់ព្រះវរបិតាសួគ៌ ។ យើងទាំងអស់គ្នាជួបនូវការផ្ទុយគ្រប់គ្រាន់ ដើម្បីនាំឲ្យយើងស្គាល់នូវក្តីស្រឡាញ់របស់ព្រះវរបិតា និងថាយើងត្រូវការជំនួយរបស់ព្រះអង្គសង្គ្រោះ ។

ព្រះអង្គសង្គ្រោះមិនមែនជាអ្នកសង្កេតដ៏ស្ងាត់នោះទេ ។ ទ្រង់ផ្ទាល់ជ្រាបនូវការឈឺចាប់ដ៏គ្មានទីបញ្ចប់ដែលយើងប្រឈមមុខជាមួយ ។ សាវកប៉ុល បានសរសេរថា ៖ « ទ្រង់រងទុក្ខការឈឺចាប់នៃមនុស្សលោកទាំងអស់ មែនហើយ គឺការឈឺចាប់របស់សត្វលោកសព្វសារពើដែលរស់នៅ ទាំងប្រុសទាំងស្រី និងក្មេងៗ »។ [5] « ដូច្នេះ ត្រូវឲ្យយើងរាល់គ្នាមកដល់បល្ល័ង្កនៃព្រះ -គុណ ដោយក្លាហាន ដើម្បីនឹងទទួលសេចក្តីមេត្តា ហើយរកបានព្រះគុណសម្រាប់នឹងជួយដល់ពេលត្រូវការចុះ » ។[6] ជួនកាលនៅក្នុងជម្រៅនៃការឈឺចាប់ ធ្វើឲ្យយើងចង់សួរថា « តើគ្មានប្រទាលមុខសេះនៅស្រុកកាឡាតទេឬអី ? តើគ្មានគ្រូពេទ្យនៅទីនោះទេឬអី ? »[7] ខ្ញុំសូមធ្វើទីបន្ទាល់ថា ចម្លើយគឺថាមានគ្រូពេទ្យម្នាក់ ។ ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទអាចព្យាបាលគ្រប់ស្ថានភាពទាំងអស់នេះ ហើយជាគោលបំណងនៃភាពរមែងស្លាប់នេះឯង ។

មានការឈឺចាប់មួយបែបទៀតដែលយើង *ត្រូវ* ទទួលខុសត្រូវ ។ ការឈឺចាប់ខាងវិញ្ញាណកប់ជ្រៅទៅក្នុងព្រលឹងរបស់យើង ហើយអាចមានអារម្មណ៍ថាមិនអាចរលត់បាន ហើយវាហាក់ដូចជា « បានញាំញី » ដោយ « សេចក្តីវេទនាដ៏មិនអាចថ្លែងបាន » ដូចដែលអាលម៉ាបានពិពណ៌នា ។[8] វាកើតចេញពីអំពើ

បាបរបស់យើង និងការខ្វះការប្រែចិត្ត ។ សម្រាប់ការឈឺចាប់នេះដែរ ក៏មានការព្យាបាលមួយ ដែលជាទូទៅ និងទាំងស្រុង ។ វាគឺមកពីព្រះវរបិតា តាមរយៈព្រះរាជបុត្រា ហើយវាគឺសម្រាប់យើងម្នាក់ៗ ដែលមានបំណងធ្វើអ្វីៗទាំងអស់ដែលចាំបាច់ដើម្បីប្រែចិត្ត ។ ព្រះគ្រីស្ទមានបន្ទូលថា « តើអ្នករាល់គ្នាមិនចង់ត្រឡប់មករកយើង ... ហើយប្រែចិត្តជឿ ដើម្បីយើងអាចប្រោសអ្នកឲ្យបានជាទេឬ ? »[9]

ព្រះគ្រីស្ទ ទ្រង់ផ្ទាល់បានបង្រៀនថា ៖ « ហើយព្រះវរបិតាយើង ទ្រង់បានចាត់ឲ្យយើងមក ដើម្បីឲ្យយើងអាចត្រូវបានលើកឡើងលើឈើឆ្កាង ហើយ *បន្ទាប់*ពីយើងត្រូវបានលើកឡើងលើឈើឆ្កាង គឺប្រយោជន៍ឲ្យយើងអាចទាញនាំមនុស្សទាំងអស់ឲ្យមករកយើង ហេតុដូច្នេះហើយ ស្របតាម*ព្រះចេស្ដា*នៃព្រះវរបិតា នោះយើងនឹងទាញនាំគ្រប់មនុស្សទាំងអស់ឲ្យមករកយើង » ។[10] ប្រហែលជាកិច្ចការសំខាន់បំផុតរបស់ទ្រង់ គឺការធ្វើការជាមួយយើងម្នាក់ៗដោយផ្ទាល់បន្តជាប់ជានិច្ច ដើម្បីលើកឡើង ប្រទានពរជ័យ ពង្រឹង គាំទ្រ ដឹកនាំ និងដើម្បីអភ័យទោសដល់យើង ។

ដូចដែលនីហ្វៃបានឃើញនៅក្នុងការនិមិត្ត ភាគច្រើននៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះគ្រីស្ទ គឺត្រូវបានបូជាចំពោះការប្រទានពរ និងព្យាបាល អ្នកឈឺ គ្រប់ជំងឺទាំងអស់ —គឺជំងឺខាងផ្លូវកាយ ផ្លូវចិត្ត និងវិញ្ញាណ ។ « ហើយខ្ញុំបានឃើញមនុស្សទាំងហ្វូង គឺពួកអ្នកឈឺ និងពួកអ្នកដែលរងទុក្ខវេទនា ដោយជំងឺគ្រប់មុខ ... ហើយទេវតាបានបង្ហាញគ្រប់រឿងទាំងអស់នេះដល់ខ្ញុំ ។ ហើយពួកគេត្រូវបានប្រោសឲ្យជា ដោយព្រះចេស្ដានៃកូនចៀមនៃព្រះ » ។[11] អាលម៉ា ក៏បានព្យាករផងដែរថា « ទ្រង់នឹងយាងទៅ ដោយរងការឈឺចាប់ និងទុក្ខវេទនា និងការល្បួងគ្រប់បែបយ៉ាង ហើយ ... ទ្រង់នឹងយកដាក់លើខ្លួនទ្រង់នូវការឈឺចាប់ និងជំងឺទាំងឡាយរបស់រាស្ត្រទ្រង់ ... *ដើម្បី* ឲ្យព្រះហឫទ័យទ្រង់បានពោរពេញទៅដោយសេចក្ដីមេត្តាករុណា *ដើម្បី* ទ្រង់អាចដឹងស្របតាមសាច់ឈាមថាតើត្រូវជួយរាស្ត្រទ្រង់បែបណា តាមជំងឺរបស់គេ » ។[12]

នាយប់ជ្រៅមួយ ពេលកំពុងសម្រាកនៅលើគ្រែក្នុងមន្ទីរពេទ្យ ពេលនេះជាអ្នកជំងឺ មិនមែនជាគ្រូពេទ្យទេ នោះខ្ញុំបានអានខទាំងនោះ ម្ដងហើយម្ដងទៀត ។ ខ្ញុំបានសញ្ជឹងគិត « តើការណ៍នេះធ្វើឡើងដោយរបៀបណា ? សម្រាប់នរណា ? តើតម្រូវឲ្យមានអ្វីខ្លះ ? តើវាដូចជាការអភ័យទោសដល់អំពើបាបឬ ? តើយើងត្រូវទទួលសេចក្ដីស្រឡាញ់ និងជំនួយរបស់ទ្រង់ឬ ? » នៅពេលដែលខ្ញុំសញ្ជឹងគិត ខ្ញុំបានយល់ថា កំឡុងពេលនៃជីវិតរមែងស្លាប់របស់ព្រះគ្រីស្ទ ទ្រង់*បានជ្រើសរើស* ដើម្បីទទួលបទពិសោធន៍នៃការឈឺចាប់ និងទុក្ខវេទនាទាំងឡាយ ដើម្បីយល់ពីពួកយើង ។ ប្រហែលយើងក៏ត្រូវទទួលបទពិសោធន៍ដ៏ពិបាកនៃជីវិតរមែងស្លាប់នេះ ដើម្បីយល់ពីទ្រង់ និងពីគោលបំណងដ៏អស់កល្បរបស់យើងផងដែរ ។[13]

ប្រធាន ហិនរី ប៊ី អាវរិង បានបង្រៀនថា ៖ « យើងនឹងត្រូវបានកម្សាន្តចិត្ត នៅពេលយើងត្រូវរង់ចាំ ទាំងព្រួយចិត្តនូវការរំដោះដែលព្រះអង្គសង្គ្រោះបានសន្យានឹងប្រទានឲ្យយើង ដោយសារទ្រង់ចេះប្រោស និងជួយយើងតាមបទពិសោធន៍ទ្រង់ ។ ...ហើយការមានសេចក្ដីជំនឿលើការណ៍នេះ នឹងធ្វើឲ្យយើងអត់ធ្មត់បាន នៅពេលយើងអធិស្ឋាន និងធ្វើការ និងរង់ចាំជំនួយ ។ ទ្រង់អាចចេះជួយយើងតាមរបៀបដ៏សាមញ្ញ គឺតាមរយៈវិវរណៈ ប៉ុន្តែទ្រង់*បានជ្រើសរើសដើម្បីរៀនតាមរយៈបទពិសោធន៍ទ្រង់ផ្ទាល់វិញ* » ។[14]

ខ្ញុំបានមានអារម្មណ៍នៃ « ការឱបក្រសោបដោយពាហុនៃសេចក្ដីស្រឡាញ់របស់ទ្រង់ »[15] នៅយប់នោះ ។ ទឹកភ្នែកស្រក់ជោគខ្នើយ ដោយការដឹងគុណ ។ ក្រោយមកទៀត នៅពេលខ្ញុំអានក្នុង ម៉ាថាយ ពីការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះគ្រីស្ទ ខ្ញុំបានរកឃើញការណ៍មួយទៀតថា ៖ « នៅពេលដែលទ្រង់មកដល់ គេនាំមនុស្សជាច្រើនមកឯទ្រង់... ហើយទ្រង់...បានប្រោសឲ្យជា *គ្រប់* គ្នាដែរ » ។[16] ទ្រង់បានប្រោសឲ្យជា *គ្រប់គ្នា* ដែលបានមកកាន់ទ្រង់ ។ គ្មាននរណាម្នាក់ដែលទ្រង់បែរចេញឡើយ ។

ដូចដែល អែលឌើរ ដាល្លិន អេក អូក បានបង្រៀនថា ៖ « ពរជ័យនៃការប្រោសឲ្យជា កើតមានតាមរបៀបជាច្រើន របៀបនីមួយៗស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗ ដូចដែលទ្រង់ជាអ្នកស្រឡាញ់យើងខ្លាំងបំផុតបានជ្រាបដឹង ។ ជូនកាល ' ការប្រោសឲ្យជា ' ព្យាបាលជំងឺរបស់យើង ឬក៏សម្រាលបន្ទុករបស់យើង ។ ប៉ុន្តែ ជូនកាល យើងត្រូវ ‹ បានប្រោសឲ្យជា › ដោយការផ្ដល់កម្លាំង ឬការយល់ដឹង ឬការអត់ធ្មត់ក្នុងការស៊ូទ្រាំបានចំពោះបន្ទុកដែលផ្ទុកមកលើយើង » ។[17] ទ្រង់ឆ្លើយតបយើង ដូចដែលទ្រង់បានឆ្លើយតបចំពោះមនុស្សទាំងអស់ ។ មនុស្សទាំងអស់ដែលនឹងមកអាចបាន « ឱបខ្ជាប់នៅក្នុងព្រះហស្តនៃព្រះយេស៊ូវ » ។[18] គ្រប់ព្រលឹងទាំងអស់អាចបានប្រោសឲ្យជាដោយព្រះចេស្ដារបស់ទ្រង់ ។ គ្រប់ការឈឺចាប់ទាំងអស់អាចបានស្រាកស្រាន្ត ។ ក្នុងទ្រង់ យើងអាច « បានសេចក្ដីសម្រាកដល់ព្រលឹង [ យើង ] » ។[19] ស្ថានភាពរមែងស្លាប់របស់យើងមិនអាចនឹងផ្លាស់ប្ដូរភ្លាមៗនោះទេ ប៉ុន្តែការឈឺចាប់ ទុក្ខព្រួយ សេចក្ដីវេទនា និងការភ័យខ្លាចរបស់យើង អាចត្រូវបានលេបបាត់នៅក្នុងសេចក្ដីសុខសាន្ត និងការប្រោសរបស់ទ្រង់ ។

ខ្ញុំបានកត់សម្គាល់ឃើញថា ជាញឹកញាប់ ក្មេងៗអត់ធ្មត់នឹងការឈឺចាប់ និងទុក្ខវេទនាបានតាមធម្មជាតិជាង ។ ពួកគេស៊ូទ្រាំដោយស្ងៀមស្ងាត់ ដោយការបន្ទាបខ្លួន និងស្លូតបូត ។ ខ្ញុំបានទទួលនូវអារម្មណ៍ដ៏ស្រស់ស្រាយ និងផ្អែមល្ហែម ដែលនៅជុំវិញក្មេងតូចៗទាំងនេះ ។

ស្សេរី អាយុដប់បីឆ្នាំ បានទទួលការវះកាត់មួយដែលមានរយៈពេលដប់បួនម៉ោង សម្រាប់សាច់ដុះនៅឆ្អឹងខ្នងរបស់នាង ។ នៅពេលនាងដឹងខ្លួនឡើងវិញនៅក្នុងបន្ទប់សង្គ្រោះបន្ទាន់ នាងបាននិយាយថា ៖ « ប៉ា មីង ឆឺរីល នៅទីនេះ ហើយ … លោកតា ន័រមិន និងលោកយាយ ប្រោន នៅទីនេះ ។ ប៉ា ចុះនរណាឈរនៅជិតប៉ា ? គាត់មើលទៅដូចប៉ាអញ្ចឹង គ្រាន់តែខ្ពស់ជាង ។ គាត់ថា គាត់ជាប្អូនរបស់ប៉ា ឈ្មោះ ជិមមី » ។ ពូរបស់នាង ជិមមី បានស្លាប់ពេលអាយុបាន 13 ឆ្នាំ ដោយសារជំងឺក្រិនប្រមាត់ ។ រយៈពេលជិតមួយម៉ោង ស្សេរី បានពណ៌នាពីអ្នកមកសួរសុខទុក្ខនាង ដែលពួកគេសុទ្ធតែជាសមាជិកគ្រួសារដែលបានស្លាប់ទៅហើយ ។ ដោយអស់កម្លាំង នាងក៏គេងលក់ទៅ ។ ក្រោយមកនាងប្រាប់ប៉ានាងថា « ប៉ា ក្មេងៗទាំងអស់នៅក្នុងបន្ទប់សង្គ្រោះបន្ទាន់នេះ មានទេវតាជួយពួកគេ » ។[20]

ទ្រង់បានមានបន្ទូលមកកាន់យើងទាំងអស់គ្នាថា ៖ « មើលចុះ អ្នករាល់គ្នាជាក្មេងតូចៗ ហើយអ្នករាល់គ្នាពុំអាចទ្រាំគ្រប់ទាំងអស់បានទេនៅពេលឥឡូវនេះ អ្នករាល់គ្នាត្រូវតែចម្រើនឡើងក្នុងព្រះគុណ និងក្នុងការចេះដឹង អំពីសេចក្ដីពិត ។ កុំឲ្យខ្លាចឡើយ កូនក្មេងតូចៗអើយ ត្បិតអ្នករាល់គ្នាជារបស់ផងយើង… ហេតុដូច្នេះហើយ យើងនៅកណ្ដាលអ្នករាល់គ្នា ហើយយើងជាអ្នកគង្វាលល្អ » ។[21]

ឧបសគ្គដ៏ធំរបស់យើងនៅក្នុងជីវិតរមែងស្លាប់ គឺការក្លាយទៅជា « អ្នកបរិសុទ្ធ តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ » ។[22] ការឈឺចាប់ ដែលអ្នក និងខ្ញុំទទួលប្រហែលជាអ្វីដែលការណ៍នេះត្រូវបានវាស់វែងខ្លាំងបំផុត ។ នៅក្នុងកាលៈទេសៈដ៏ពិបាកបំផុត យើងអាចក្លាយដូចជាក្មេងតូចៗនៅក្នុងដួងចិត្តរបស់យើង បន្ទាបខ្លួនយើង និង « អធិស្ឋាន និងធ្វើ និងរង់ចាំ »[23] ដោយអត់ធ្មត់ សម្រាប់ការប្រោសឲ្យជាដល់ព្រលឹង និងរូបកាយរបស់យើង ។ ដូចជាយ៉ូប បន្ទាប់ពីបានដុសខាត់បន្សុទ្ធដោយការសាកល្បងរបស់យើងហើយ យើងនឹង « ចេញមកដូចជាមាស » ។[24]

ខ្ញុំថ្លែងទីបន្ទាល់ថា ទ្រង់ជាអង្គប្រោសលោះរបស់យើង ជាមិត្តរបស់យើង ជាព្រះដ៏គាំទ្រ ជាគ្រូពេទ្យដ៏ពូកែ ជាអ្នកប្រោសដ៏អស្ចារ្យ ។ នៅក្នុងទ្រង់ យើងអាចរកឃើញសេចក្ដីសុខសាន្ត និងភាពធូរស្រាល នៅក្នុង និងពីការឈឺចាប់ និងអំពើបាបរបស់យើង ។ បើយើងគ្រាន់តែមកកាន់ទ្រង់ជាមួយនឹងដួងចិត្តដ៏ទន់ទាប ។ « ព្រះគុណរបស់ទ្រង់គឺល្មមគ្រប់គ្រាន់ » ។[25] នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. Orson F. Whitneyក្នុង in Spencer W. Kimball, *Faith Precedes the Miracle* ( ឆ្នាំ 1972 ) ទំព័រ 98 ។
2. Robert D. Hales « Healing Soul and Body » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1998 ទំព័រ 14 ។
3. សូមមើល អាលម៉ា 31:31, 33 ។
4. នីហ្វៃទី2 2:1 ។
5. នីហ្វៃទី2 9:21
6. ហេព្រើ 4:15–16 ។ ប៉ុលបានបង្រៀនយើង ឲ្យមើលទៅព្រះអង្គសង្គ្រោះ ជាគំរូនៅក្នុងការដោះស្រាយជាមួយ « ការទ្រាំទ្រនឹងមនុស្សមានបាបដែលធ្វើទទឹងទទែងនឹង [ យើង ] ក្រែង [ យើង ] ត្រូវនឿយហត់ ហើយរសាយចិត្តចេញ » ( ហេព្រើ 12:3 ) ។
7. យេរេមា 8:22 ។
8. អាលម៉ា 36:14 ។
9. នីហ្វៃទី3 9:13 ។
10. នីហ្វៃទី3 27:14–15; អត្ថន័យពិសេសត្រូវបានបន្ថែម ។
11. នីហ្វៃទី1 11:31 ។
12. អាលម៉ា 7:11–12; អត្ថន័យពិសេសត្រូវបានបន្ថែម ។
13. សូមមើល John Taylor *Mediation and Atonement* ឆ្នាំ 1882 ជំពូក XI ទំព័រ 97 ។ លោកសរសេរពី « សេចក្ដីសញ្ញា » ដែលត្រូវបានដាក់បញ្ចូលនៅរវាងព្រះវរបិតា និងព្រះរាជបុត្រា នៅក្នុងការប្រជុំប្រឹក្សានៅជីវិតមុនផែនដី សម្រាប់ការសម្រេចបាននៃការប្រោសលោះដ៏ធួននៃមនុស្សទាំងអស់ ។ ការរងទុក្ខដោយស្ម័គ្រចិត្តរបស់ទ្រង់ក្នុងជីវិត គឺជាការបន្ថែមទៅដល់ការរងទុក្ខនៅក្នុងសួនច្បារ និងនៅលើឈើឆ្កាង ។ សូមមើលផងដែរ ម៉ូសាយ 3:5—8 ។
14. Henry B. Eyring « Adversity » *លីអាហូណា* និង *Ensign* ខែ ឧសភា ឆ្នាំ 2009 ទំព័រ 23–27 អត្ថន័យពិសេសត្រូវបានបន្ថែម ។

15. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 6:20 ។
16. ម៉ាថាយ 8:16–17 អត្ថន័យពិសេសត្រូវបានបន្ថែម ។
17. Dallin H. Oaks « He Heals the Heavy Laden » *លីអាហូណា* និង *Ensign* ខែ វិច្ឆិកា ឆ្នាំ 2006 ទំព័រ 7–8 ។
18. មរមន 5:11 ។
19. ម៉ាថាយ 11:29 ។
20. Michael R. Morris « Sherrie′s Shield of Faith » *Ensign* ខែ មិថុនា ឆ្នាំ 1995 ទំព័រ 44 ។
21. គោលលទ្ធិ និងសេចក្ដីសញ្ញា 50:40–41, 44 ។
22. ម៉ូសាយ 3:19 ។
23. Henry B. Eyring *លីអាហូណា* និង *Ensign* ទំព័រ 24 ។
24. យ៉ូប 23:10 ។
25. សូមមើល កូរិនថូសទី 2 12:9; អេធើរ 12:26–27 គោលលទ្ធិ និងសេចក្ដីសញ្ញា 18:31 ។